សលាកប័ត្រព័ត៌មាន NEWSLETTER
លេខៈ ៤៦ ខែកញ្ញា-តុលា ឆ្នាំ២០០៩
Issue: 46 September-October 2009

ឃ្លាំមើល សាលាក្តីខ្មែរក្រហម
KHMER ROUGE TRIBUNAL (KRT) WATCH

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ_សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP - IDA - KKKHRO - KKKHRDA - KID - KIND - KSA - KYA - LAC - PDP -PJJ - VIGILANCE

# សហព្រះរាជអាជ្ញាអន្តរជាតិចោទប្រកាន់ជនសង្ស័យ អតីតមេដឹកនាំខ្មែរក្រហមបន្ថែម

លោក**វីល្លៀម ស្មីត** បន្ទាប់ពីត្រូវបានតែងតាំងជាសហព្រះរាជអាជ្ញាអន្តរជាតិស្តីទីជំនួសលោក **រ៉ូបើត ប៉ីទីត** ដែលបានលាលែងកាលពី ២ ខែមុន បានបញ្ជូនដីកាបញ្ជូនរឿងឱ្យស៊ើបសួរទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេតបានរួចរាល់ហើយ ដើម្បីអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបអង្កេតទៅលើឧក្រិដ្ឋកម្មនានាដែលមាននៅក្នុងដីកានោះ យោងទៅតាមសេចក្តីថ្លែងការណ៍ប្រកាស កាលពីថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៩ កន្លងទៅនេះ។


*លោក វីល្លៀម ស្មីត (ឈរនៅក្នុងសវនាការ)*

សេចក្តីថ្លែងការណ៍នេះ បានធ្វើការគូសបញ្ជាក់ថា ការបញ្ជូនរឿងឱ្យស៊ើបអង្កេត មកពីខាងការិយាល័យសហព្រះរាជអាជ្ញាអន្តរជាតិតែឯងបែបនេះ គឺដោយសារថា នាពេលថ្មីនេះ អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា បានចេញសេចក្តីសំរេចជុំវិញបញ្ហាខ្វែងមតិគ្នាអំពីការចោទប្រកាន់ជនសង្ស័យថ្មីបន្ថែម កាលពីថ្ងៃទី២ ខែកញ្ញា កន្លងទៅនេះ។

សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានលើកឡើងថា ដោយយោងទៅតាមការស៊ើបអង្កេតបឋម គេរកឃើញថាមានការពាក់ព័ន្ធ នឹងស្ថានភាពបទល្មើសច្រើន ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ហើយក៏ស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការនេះដែរ ដែលរួមមានដូចជាៈ អំពើមនុស្សឃាត, អំពើទារុណកម្ម, ការឃុំឃាំងដោយខុសច្បាប់, ការបង្ខំឱ្យធ្វើការជាទំងន់ និងអំពើធ្វើទុក្ខបុកម្នេញផ្សេងៗជាដើម។ តាមការបញ្ជាក់នៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះ អំពើដែលបានកំណត់ទាំងអស់នេះមានជាប់ពាក់ព័ន្ធផងដែរទៅដល់អ្នកទទួលខុសត្រូវ ឬមេដឹកនាំខ្មែរក្រហម៥នាក់ផ្សេងទៀត ក្រៅពី **កាំង ហ្គេកអ៊ាវ ហៅ ឌុច, នួន ជា, ខៀវ សំផន, អៀង សារី និងអៀង ធីរិទ្ធ** ដែលបានប្រមុខនឹងការកាត់សេចក្តីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នាពេលបច្ចុប្បន្ននេះ។ ដោយសារតែនីតិវិធីមានលក្ខណៈសំងាត់ ដូចនេះយោងទៅតាមសេចក្តីថ្លែងការណ៍នេះ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីមិនបានគូសបញ្ជាក់ឱ្យបានច្បាស់ថា ជនដែលត្រូវបានចោទប្រកាន់ជាបឋមនោះ នៅក្នុងសំណុំរឿងថ្មី (សំណុំរឿង ០០៣) នេះ ជាអ្នកណានោះឡើយ។

នៅក្នុងសេចក្តីថ្លែងការណ៍ដដែលនេះ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានគូសបញ្ជាក់ច្បាស់ថា នឹងមិនមានជនសង្ស័យផ្សេងទៀតដែលនឹងអាចប្រឈមមុខនឹងការចោទប្រកាន់បន្ថែមនោះទេ គឺថា មានតែជនសង្ស័យ៥នាក់ថ្មី ដែលមានឈ្មោះនៅក្នុងដីកាស៊ើបបញ្ជូនរឿងឱ្យស៊ើបសួរនេះតែប៉ុណ្ណោះ ដែលជាអ្នកចុងក្រោយគេ ដោយសារថា ការកាត់សេចក្តីទៅលើជនសង្ស័យបន្ថែមផ្សេងទៀត នឹងធ្វើឱ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះកាន់តែបានពេញលេញ។

គួរបញ្ជាក់ផងដែរថា នៅមុនពេលចេញដីកានេះសហព្រះរាជអាជ្ញាជាតិ លោកស្រី **ជា លាង** បានជំទាស់រួចហើយ ពីព្រោះថា លោកស្រីយល់ឃើញថាមិនចាំបាច់ និងអាចបណ្តាលឱ្យមានអស្ថិរភាពសង្គមកម្ពុជាផងដែរ។ ដោយសារតែការខ្វែងមតិនេះហើយ ទើបភាគី សហព្រះរាជអាជ្ញាអន្តរជាតិជាសមភាគីរបស់លោកស្រី ដែលកាលនោះ គឺលោក **រ៉ូបើត ប៉ីទីត** បានប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះហើយ ទីបំផុតបញ្ហាដ៏ចំរូងចំរាស់នេះក៏ត្រូវបានអង្គបុរេជំនុំជម្រះ ដែលមានចៅក្រម៥រូបសម្រេចសេចក្តី គឺថា**ចៅក្រមកម្ពុជា៣រូបមិនគាំទ្រការចោទប្រកាន់បន្ថែម** ខណៈពេលដែល**ចៅក្រមអន្តរជាតិ២រូបមិនជំទាស់នឹងការចោទប្រកាន់បន្ថែម** ដែលស្នើដោយភាគីសហព្រះរាជអាជ្ញាអន្តរជាតិ។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ កិច្ចការចោទប្រកាន់

ជនសង្ស័យបន្ថែមនេះនៅមិនទាន់បញ្ចប់នៅឡើយទេ ដោយសារថា គេនៅមិនទាន់ដឹងច្បាស់ថានឹងមានរឿងអ្វីកើតឡើងតទៅទៀតរវាងសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះ បញ្ហាដដែលនេះ ពីព្រោះថា ប្រសិនបើមិនមានការឯកភាពនៅក្នុងចំណោមសហចៅក្រមស៊ើបអង្កេតទាំងពីរទេ ភាគីណាមួយក៏អាចប្ដឹងឧទ្ធរណ៍ការជំទាស់ដោយភាគីណាមួយទៅអង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីសម្រេចសេចក្ដី ឱ្យបាន។

ចំពោះបញ្ហាការចោទប្រកាន់ជនសង្ស័យណាម្នាក់អាចធ្វើទៅបាន ជាគោលការណ៍ សហព្រះរាជអាជ្ញាត្រូវកំណត់ថាតើជននោះ ស្ថិតនៅក្នុងក៏រិតជា **"មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត"** ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរយៈកាលពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩ ដូច បានកំណត់ច្បាស់នៅក្នុងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ក៏ដូចជាច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ប៉ុន្ដែទោះបីជាយ៉ាងនេះក៏ដោយ ជុំវិញបញ្ហានេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានប្រតិកម្មខ្លាំងៗ ពីព្រោះលោកយល់ថា បញ្ហាចោទប្រកាន់ទៅលើអតីតមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវផ្សេងទៀតទាំងនោះ អាចបង្កឱ្យមានអស្ថិរភាពសង្គមកម្ពុជា ឬក៏អាចនាំឱ្យមានជំលោះកើតឡើងសាជាថ្មីម្ដងទៀត ហើយជាលទ្ធផល នោះវានឹងប៉ះពាល់ទៅដល់កិច្ចខិតខំប្រឹងប្រែងក្នុងការថែរក្សាសន្ដិភាព អភិវឌ្ឍន៍ប្រទេសជាតិក្រោយពីរបបខ្មែរក្រហម ក៏ដូចជាមិនចង់ឱ្យប៉ះពាល់ដល់ការបង្រួបបង្រួមជាតិនាពេលបច្ចុប្បន្នដែរ។ ជាក់ស្ដែង កាលពីអំឡុងដើមខែកញ្ញានេះ លោកនាយករដ្ឋមន្ត្រី មានប្រសាសន៍ខ្លាំងៗទាក់ទិនបញ្ហានេះ ជាហេតុធ្វើឱ្យមានការព្រួយបារម្ភអំពី ឯករាជ្យភាព ក៏ដូចជា ដំណើរការឈានឆ្ពោះទៅមុខរបស់សាលាក្ដីខ្មែរក្រហមនេះ ពីសំណាក់ មជ្ឈដ្ឋានទូទៅ នៅខណៈពេលដែលដំណើរការកាត់សេចក្ដីទៅលើ ជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** កំពុងធ្វើជាបន្តបន្ទាប់។

លោក **ប្រេត អាដាម** ប្រធានអង្គការ Human Rights Watch (ឃ្លាំមើលសិទ្ធិមនុស្ស) ប្រចាំអាស៊ី យល់ឃើញថា ការដែល លោកនាយករដ្ឋមន្ត្រី ទាមទារជាបន្តបន្ទាប់ឱ្យសាលាក្ដីខ្មែរក្រហម កំណត់ចំនួនមនុស្សដើម្បីកាត់សេចក្ដីនោះ វាបង្ហាញជាថ្មីម្ដងទៀតនូវ ការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជាជ្រៀតជ្រែកទៅលើអ្វី ដែលជាគួរ តែកាត់សេចក្ដីប្រកបដោយភាពឯករាជ្យហើយ។ លោកបានបន្ថែម ទៀតថា ការសម្រេចចិត្តណាមួយរបស់តុលាការនេះគួរតែផ្អែកទៅលើ ភស្តុតាង មិនមែនដោយការពិចារណាហេតុផលនយោបាយនោះទេ។

ចំណែកលោក **នូត រូសាន់ហាក់** (Knut Rosandhaug) អនុប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ ធ្លាប់បានបង្ហាញការយល់ឃើញថា ការសម្រេចបែបចោទប្រកាន់បន្ថែមនេះ វាគឺជាស្តង់ដារអន្តរជាតិ ដែលត្រូវបង្កើតឡើងច្បាស់លាស់មួយ ដែលថាតុលាការនេះមិនសុំការអនុញ្ញាត ឬសុំយោបល់អំពីការងាររបស់ខ្លួនពីនីតិប្រតិបត្តិ។ លោកក៏សង្ឃឹមទៀតថា សាលាក្ដីនេះនឹងអនុលោមទៅតាមស្តង់ដារយុត្តិធម៌អន្តរជាតិដែលទទួលស្គាល់ និងធ្វើការសម្រេចចិត្ត ដោយឈរលើគោលការណ៍ឯករាជ្យពេញលេញ។

# បញ្ចប់ការសាកសួរសាក្សីនៅក្នុងសវនាការ "ឌុច"



*ជនជាប់ចោទ ឌុច នៅរង្វង់ក្រចកសេះចំពោះមុខអង្គជំនុំជម្រះសាលាដំបូង*

ខណៈដែលមានមជ្ឈដ្ឋានខ្លះ ចាប់អារម្មណ៍ពីប្រតិកម្មរបស់លោកនាយករដ្ឋមន្ត្រីទៅលើការបញ្ជូនរឿងឱ្យស៊ើបអង្កេតទៅលើជនសង្ស័យថ្មីផ្សេងទៀត នៅប៉ុន្មានសប្ដាហ៍ចុងក្រោយនៃខែកញ្ញា ឆ្នាំ២០០៩ នេះ អង្គជំនុំជម្រះសាលាដំបូង នៃសាលាក្ដីខ្មែរក្រហម នៅតែបន្តសវនាការជំនុំជម្រះទៅលើអតីតប្រធានមន្ទីរស-២១ ឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ "**ឌុច**"ដដែល។ នៅក្នុងសវនាការនៃថ្ងៃបន្តបន្ទាប់នេះ អង្គជំនុំជម្រះសាលាដំបូងបានកោះហៅសាក្សីជំនាញ និងសាក្សីផ្សេងៗ ជាច្រើនទៀត ដែលធ្លាប់មិត្តភក្ដិ និងកូនសិស្សរបស់ជនជាប់ចោទ **ឌុច** ដើម្បីឡើងផ្ដល់សក្ខីកម្មជូនអង្គចៅក្រមជុំវិញ ***"បញ្ហាផ្លូវចិត្ត និង បញ្ហាអត្តចរិត"*** របស់ជនជាប់ចោទរូបនេះ។

សាក្សីដែលឡើងមកបំភ្លឺជាបន្តបន្ទាប់ទាក់ទិននឹងបញ្ហានេះ គឺភាគច្រើនជាសាក្សីរបស់ខាងមេធាវីការពាររបស់ **ឌុច** ដើម្បីផ្ដល់សក្ខីកម្មជូនអង្គចៅក្រម ដែលនៅក្នុងនោះរួមដូចជា៖ សាក្សីជាកូនសិស្សរបស់ **ឌុច** នៅមុនឆ្នាំ១៩៧៥ និងសាក្សីជា មិត្តភក្ដិនៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ និងគ្រូគង្វាលសាសនា

គ្រីស្តរបស់ **ឌុច** (ឌុច ប្តូរមកជាគ្រីស្តសាសនិកជនវិញរហូតមកទល់ពេលបច្ចុប្បន្ន) ផងដែរ។

ជាដំណើរការនីតិវិធីតុលាការ គឺថាការដែលកោះហៅសាក្សីទាំងនោះ មកផ្តល់សក្ខីកម្មអំពីស្ថានភាពផ្លូវចិត្ត និងអត្តចរិតរបស់ជនជាប់ចោទ **ឌុច** នៅចំពោះមុខអង្គចៅក្រម គឺដើម្បីស្វែង យល់ និងរកឱ្យឃើញការពិតដែលថា ជននេះពិតជាមនុស្សមានស្មារតីត្រឹមត្រូវពេញលេញដែលត្រូវទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋ ដែលបានកើត ឡើងនៅក្នុងកំឡុងពេលដែលខ្លួនកាន់អំណាច ក្នុងឋានៈជាប្រធានមន្ទីរស-២១ ដែលបណ្តាលឱ្យអ្នកទោស ឬអ្នកជាប់ឃុំជាង ១៣000 នាក់ស្លាប់។

នៅក្នុងចំណោមសាក្សី ដែលមានវត្តមានបំភ្លឺអង្គសវនាការនាពេលនោះ ក៏មានសាក្សីខ្លះបង្ហាញវត្តមានផ្ទាល់ និងក៏មានសាក្សីខ្លះទៀត បានផ្តល់សក្ខីកម្មតាមរយៈកាមេរ៉ាពីក្រៅប្រទេសផងដែរ។ សាក្សីអ្នកជំនាញផ្នែកចិត្តសាស្ត្រពីររូប គឺលោកស្រី **ហ្វ្រង់ស្វ័រ ស៊ីលបូនី ហ្គីលបូ** (Françoise Silboni-Guilbaud) **និងលោក ការ ស៊ុន បូណា** បានពន្យល់ប្រាប់អង្គចៅក្រមដោយត្រួសៗតាមរយៈបច្ចេកទេស និងជំនាញរបស់គាត់ថា ការពិតជនជាប់ចោទ **ឌុច** មិនមានបញ្ហាខាងផ្លូវចិត្ត ឬអារម្មណ៍អ្វីនោះទេ ហេតុដូច្នេះហើយបានជាគាត់អាចចូលរួមយ៉ាងពេញលេញនៅក្នុងការកាត់សេចក្តីនាពេលនេះ។

ចំណែកឯសាក្សីខាងផ្នែកអត្តចរិតចំនួន៦រូបផ្សេងទៀត ដែលធ្លាប់ជាមិត្តភក្តិ និងជាកូនសិស្សរបស់ជនជាប់ចោទរូបនេះវិញ សុទ្ធតែបាន បញ្ជាក់ប្រាប់អង្គជំនុំជម្រះសាលាក្តីខ្មែរក្រហមថា **ឌុច** គឺជា មនុស្សល្អ មានអត្តចរិតសុភាព និងស្ងាត់ស្ងៀម ប៉ុន្តែគេមិនដឹងថាហេតុអ្វីបាន ក្រោយមកនៅពេលដែលគាត់បានក្លាយទៅប្រធានមន្ទីរ ស-២១ នៅក្នុងសម័យខ្មែរក្រហម ប្រែជាមានចរិតសាហាវឃោរឃៅទៅវិញ។

ដោយឡែក នៅក្នុងសវនាការរយៈពេលប៉ុន្មានសប្តាហ៍ចុងក្រោយនេះដែរគេក៏សង្កេតឃើញអវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលសវនាការ ពីព្រោះថា ពួកគាត់បានធ្វើពហិការជំទាស់ទៅនឹងការសំរេចរបស់អង្គចៅក្រម ក្នុងការមិនអនុញ្ញាតឱ្យមេធាវីរបស់គាត់បានចោទសួរទៅសាក្សីនានា ដែលឡើងមកផ្តល់សក្ខីកម្មអំពីបញ្ហាផ្លូវចិត្ត និងអត្តចរិតរបស់ជនជាប់ចោទ។ ប៉ុន្តែទោះបីជាអវត្តមានដើម បណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះនៅ តែបង្ហាញខ្លួននៅក្នុងអង្គសវនាការ និងបានលើកឡើងនូវហេតុផលនៃ ការធ្វើពហិការមិនចូលរួមរបស់ កូនក្តីខ្លួនដែលធ្លាប់តែចូលរួមអង្គុយ ស្តាប់យ៉ាងហោចណាស់ក៏មាន ចំនួន១០ នាក់ ជូនអង្គចៅក្រមជំនុំជម្រះផងដែរ។

មកត្រឹមថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ និងក្រោយពីការបញ្ចប់ការសាកសួរទៅលើសាក្សី និងអ្នកជំនាញ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសបញ្ចប់នូវការបង្ហាញភស្តុតាងរបស់គូរភាគី និងការសាកសួរសាក្សី និង អ្នកជំនាញនានា ហើយកំណត់ថា ការធ្វើសេចក្តីសន្និដ្ឋានដោយភាគីនឹងត្រូវធ្វើបន្តទៅទៀត នៅថ្ងៃទី២៣ ខែវិច្ឆិកាខាងមុខនេះ។

គួរបញ្ជាក់ផងដែរថា បើយោងទៅតាមទិន្នន័យសរុបដោយការិយាល័យកិច្ចការសាធារណៈបានប្រកាសឱ្យដឹងថា សវនាការទៅជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** នេះ បានប្រព្រឹត្តធ្វើឡើងអស់រយៈពេល ៧២ ថ្ងៃ ហើយ គិតចាប់តាំង ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ដែលក្នុងនោះមានការផ្តល់សក្ខីកម្មពីសាក្សីអ្នកជំនាញ ៩រូប, សាក្សីអង្គហេតុ១៧រូប, សាក្សីផ្នែកអត្តចរិត៧រូប និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន២២រូប (ក្នុងចំណោម៩៣រូប) និងមានអ្នកចូលរួមតាមដានស្តាប់សវនាការ និងទស្សនាចំនួន២៣,៧៤២ នាក់ ដែលមកពីខេត្ត/ក្រុងមួយចំនួន រួមទាំងនិស្សិត បុគ្គលិករាជការផ្សេងៗ ផងដែរ។

## សារចំបងសំរាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២

កាលពីពេលថ្មីៗនេះ អង្គភាពជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសេចក្តីជូនដំណឹងមួយជូនចំពោះជនរងគ្រោះនៃរបបខ្មែរក្រហមទាំងឡាយ ដែលមានបំណងចង់ដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសនៅក្នុង សំណុំរឿងលេខ០០២ ដែលមានជនត្រូវចោទចំនួនបួនរូប ដែលត្រូវបានអង្គជំនុំជម្រះវិសាមញ្ញចាត់ទុកថាជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជា ប្រជាធិបតេយ្យ។ ការចេញសេចក្តីជូនដំណឹងនេះ ខណៈពេលដែលសំណុំរឿង ០០២ នេះ កំពុងត្រូវបានស៊ើបអង្កេតបន្ថែមដោយសហចៅក្រមស៊ើបអង្កេតដែលមាន លោក **យូ ប៊ុនឡេង** និងលោក **ម៉ារ៉សែល ឡឺម៉ុងដ៍** និងដែលត្រូវគេរំពឹងថា **នឹងអាចត្រូវបញ្ចប់នៅដំណាច់ចុងឆ្នាំ ២០០៩** ខាងមុខនេះ។

យោងតាមនីតិវិធីដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងបច្ចុប្បន្ន ពេលផុតកំណត់ទទួលពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី **មានរយៈពេល ១៥ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីការបញ្ចប់ដំណើរការស៊ើបអង្កេត ដោយសហចៅក្រមស៊ើបអង្កេត**។ ដូចនេះមានន័យថា ប្រសិនបើ ជនរងគ្រោះទាំងឡាយណាដែលមានបំណងចង់ចូលរួមនៅ ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ត្រូវអញ្ជើញមកដាក់ពាក្យបណ្តឹងនោះឱ្យបានមុនកាលកំណត់នេះដោយបំពេញទៅតាមទំរង់ព័ត៌មានរបស់ជនរងគ្រោះដែលចេញដោយអង្គភាពជនរងគ្រោះ ដើម្បីឱ្យសហចៅក្រមស៊ើបអង្កេត ក៏ដូចជាអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់នៅក្នុងសំណុំរឿង ០០២ នេះ។



*អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី-វេទិកាសមាគមអាដហុក*

ដើម្បីចៀសវាងនូវការយឺតយ៉ាវណាមួយក្នុងការប្រតិបត្តិការពាក្យបណ្ដឹង ដែលទទួលបានពីជនរងគ្រោះទាំងនេះនៅពេលខាងមុខ អង្គភាពជនរងគ្រោះ បានស្នើសុំឱ្យបញ្ជូនកាន់ការិយាល័យរបស់ខ្លួនឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ឱ្យបាន**មុនពាក់កណ្ដាល ខែវិច្ឆិកា ឆ្នាំ២០០៩** ខាងមុខនេះ។ ការធ្វើបែបនេះ គឺដើម្បីទទួលបាននូវចំណាប់អារម្មណ៍កាន់តែច្រើន និងផលប្រយោជន៍ផ្សេងទៀតពីការដាក់ឯកសាររបស់អង្គភាពជនរងគ្រោះ និងការិយាល័យសហចៅក្រមស៊ើបអង្កេត ក៏ដូចជាជួយបំពេញព័ត៌មានបន្ថែមទៀតប្រសិនបើខ្វះចន្លោះ។

ដូចនេះ ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រឹមត្រូវ និងទទួលយកបានដោយសហចៅក្រមស៊ើបអង្កេត អង្គភាពជនរងគ្រោះ បានណែនាំឱ្យបំពេញ**ព័ត៌មានចាំបាច់**ដូចខាងក្រោម:

- ឈ្មោះជនរងគ្រោះម្នាក់ ឬច្រើននាក់ និងឈ្មោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។
- អាស័យដ្ឋាននៅកម្ពុជារបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។
- ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី។
- រាល់ព័ត៌មានដែលអាចរកបាន ដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមួយ ឬច្រើនដូចដែលបានចោទ។
- ភស្តុតាងបញ្ជាក់អត្តសញ្ញាណ នៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អាចជា: សំណៅថតចំលង នៃអត្តសញ្ញាណប័ណ្ណ, សៀវភៅគ្រួសារ ឬលិខិតចេញដោយអាជ្ញាធរឃុំ/សង្កាត់ ឬអាជ្ញាធរថ្នាក់ខ្ពស់ជាង។ បើអាចធ្វើបាន លិខិតបញ្ជាក់នោះគួរមានបោះត្រាត្រឹមត្រូវផងដែរ។
- ប្រសិនបើអាចរកបានរាល់ឯកសារដែលគាំទ្រដល់ព័ត៌មានផ្ដល់ ដោយអ្នកដាក់ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឧទាហរណ៍រូបថតជនរងគ្រោះ។

រាល់ព័ត៌មានបន្ថែម សំរាប់ការជួយបំពេញទំរង់ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ ជនរងគ្រោះក៏អាចទាក់ទងដោយផ្ទាល់មកការិយាល័យអង្គភាពជនរងគ្រោះ ឬតាមរយៈអង្គការអន្តរការីមួយចំនួនដែលប្រតិបត្តិការនៅតាមខេត្ត/ក្រុងនានា ដូចជា សមាគមអាដហុក វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ និងសមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម ជាដើម។

ជនត្រូវចោទទាំងបួនរូបនៅក្នុងសំណុំរឿង០០២ ដែលកំពុងត្រូវបានដាក់ឱ្យនៅក្នុងមន្ទីរឃុំខ្លួនបណ្ដោះអាសន្ន រួមមាន: លោក **នួន ជា** អាយុ ៨៣ឆ្នាំ (បងធំទី២ និងជាអតីតប្រធានរដ្ឋសភា), លោក **អៀង សារី** អាយុ ៨៤ឆ្នាំ (អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការបរទេស), លោកស្រី **អៀង ធីរិទ្ធ** អាយុ ៧៧ឆ្នាំ (អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច) និងលោក **ខៀវ សំផន** អាយុ ៧៨ឆ្នាំ (អតីតប្រធានគណៈប្រធានរដ្ឋ) នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានកាន់កាប់អំណាចនៅប្រទេសកម្ពុជាពីថ្ងៃ ១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩។

ជនរងគ្រោះអំពើហិង្សាផ្លូវភេទរវាងឆ្នាំ១៩៧៥-១៩៧៩
សូមទាក់ទង: អង្គការអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
អាសយដ្ឋាន: ផ្ទះ១២ ផ្លូវ២៨២ សង្កាត់បឹងកេងកង១
ខណ្ឌចំការមន
ទូរស័ព្ទ: ០២៣ ៧៣០ ០៣២
០១២ ៩១៤ ៥៣២

*ទស្សនៈទាំងឡាយដែលមាននៅក្នុងអត្ថបទនៃសលាកប័ត្រព័ត៌មាននេះ មិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់ ឌី.អ៊ី.ឌី(DED) ទេ។*

**ឧបត្ថម្ភមូលនិធិដោយ: ឌី.អ៊ី.ឌី**

## ព័ត៌មានសំខាន់:

➢ ប្រសិនបើលោកអ្នកចាប់អារម្មណ៍ចង់ចូលរួមដាក់ពាក្យបណ្ដឹង**ជាភាគីដើមបណ្ដឹងរដ្ឋប្បវេណី** និង**ជាសាក្សីនៅចំពោះមុខសាលាក្ដីខ្មែរក្រហម**

**សូមទាក់ទង:**

- **សមាគមអាដហុក (ADHOC)**
  លេខទូរស័ព្ទ: ០២៣ ៩៩០ ៥៤៤, ០២៣ ២១៨ ៦៥៣
- វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ **(KID)**
  លេខទូរស័ព្ទ: ០២៣ ២១៤ ៩២៨
- មជ្ឈមណ្ឌលអភិវឌ្ឍន៏សង្គម **(CSD)**
  លេខទូរស័ព្ទ: ០២៣ ៣៦៤ ៧៣៥
- សមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម **(KKKHRA)**
  លេខទូរស័ព្ទ: ០២៣ ៩៩៣ ៤៨៦
- អង្គភាពជនរងគ្រោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
  លេខទូរស័ព្ទ: ០២៣ ២១៤ ២៩១

➢ ស្ដាប់កម្មវិធីឃ្លាំមើលសាលាក្ដីដែលមានផ្សាយបន្តផ្ទាល់ និងចាក់ផ្សាយឡើងវិញតាមវិទ្យុ FM ១០២ រៀងរាល់ ថ្ងៃពុធ ម៉ោង ៥:៣០ - ៦:៣០ ល្ងាច ។
➢ សូមស្រាវជ្រាវព័ត៌មានបន្ថែមលើគេហទំព័រ www.krtrial.info